# The Baptist Tabernacle of Los Angeles

Mailing Address:
P. O. Box 15308
Los Angeles, CA 90015
Phone: (213) 744-9999
E-mail: rlhymersjr@sbcglobal.net
www.sermonsfortheworld.com
www.baptisttabernacle.com




Dr. Christopher L. Cagan
Pastor

Dr. R. L. Hymers, Jr.
Pastor Emeritus

ធ្នូ ២០២០

ជូនចំពោះមិត្តភ័ក្តិជាទីស្រឡាញ់៖

ម៉េចក៏មានភាពរញ៉េរញ៉ៃរបស់សាតាំង ច្រើនម្ល៉េះ ដែលយើងបានរស់នៅក្នុងឆ្នាំ២០២០! ប្រធានាធិបតីត្រូវបានគេចោទប្រកាន់! ជំងឺក្លូណាបានវាយប្រហារ! ភ្លើងឆេះព្រៃបានបំផ្លាញព្រៃរបស់យើងជាច្រើន! ប្រជាជនដើរតាមពួកកុម្មុយនិស្តហើយបានដុតបំផ្លាញទីក្រុងរបស់យើង! ខ្ញុំមិនអាចក្រោកឈរឡើងដើម្បីអធិប្បាយបានទៀត! « អ្នកខ្លះនឹងលាកចាកចេញពីសេចក្ដីជំនឿ ដោយស្តាប់តាមវិញ្ញាណបញ្ឆោត និងសេចក្ដីបង្រៀនរបស់ពួកអារក្ស ដោយសារពុតមាយារបស់ពួកអ្នក ដែលពោលតែពាក្យកុហក ទាំងមានបញ្ញាចិត្តរលាក » (១ ធីម៉ូថេ ៤ :១,២)។ សូម្បីតែលោកប៉ាប(សាសនាកាតូលិក)ក៏បានយល់ព្រមនឹងការរួបរួមភេទដូចគ្នាដែរ! វាហាក់ដូចជាលោកីយទាំងមូលបានត្រៀមខ្លួនដើម្បីផ្ទុះរួចហើយ ព្រះយេស៊ូវមានបន្ទូលថា៖

> «កាលណោះ នឹងមានទីសំគាល់នៅក្នុងព្រះអាទិត្យ ក្នុងព្រះចន្ទ និងក្នុងអស់ទាំងផ្កាយ ហើយនៅលើផែនដី នឹងមានសេចក្ដីលំបាកនៅគ្រប់ទាំងសាសន៍ និងសេចក្ដីទ័លគំនិត ដោយព្រោះសូរសន្ធឹករបស់សមុទ្រ និងរលក ២៦ មនុស្សនឹងស្រយុតចិត្តដោយភ័យ ហើយដោយទន្ទឹងចាំការដែលត្រូវមកលើផែនដី ដ្បិតអស់ទាំងអំណាចនៅលើមេឃ នឹងត្រូវកក្រើករំពើក ២៧ នោះគេនឹងឃើញកូនមនុស្សមកលើពពក មានទាំងព្រះចេស្ដា និងសិរីល្អជាខ្លាំង ២៨ កាលណាការទាំងនេះចាប់តាំងកើតមក នោះឲ្យអ្នករាល់គ្នាងើបមើលទៅលើ ពីព្រោះសេចក្ដីប្រោសលោះរបស់អ្នករាល់គ្នាជិតដល់ហើយ» (លូកា ២១:២៥-២៨)។

> «ប៉ុន្តែ ទោះទាំងឪពុកម្ដាយ បងប្អូន ញាតិសន្តាន ហើយមិត្រសំឡាញ់ក៏នឹងបញ្ជូនអ្នករាល់គ្នា ហើយនឹងសំឡាប់អ្នករាល់គ្នាខ្លះដែរ» (លូកា ២១:១៦)។

តើយើងអាចអានអត្ថបទគម្ពីរទាំងនេះ ហើយមិនឃើញថា យើងកំពុងរស់នៅក្នុងចុងក្រោយបង្អស់ដែលជាពាក្យ ក្នុងព្រះគម្ពីរយ៉ាងម៉េចបាន?

«តែ អ្នកនិយាយថា វាជាគ្រាបុណ្យណូអែល» ក្នុងខែធ្នូរ ឆ្នាំ១៩៤១ លោកឆើចឆីលមកពីប្រទេសអង់គ្លេសបាននៅទីនេះដោយសារតែជន ជាតិជប៉ុនបានដាក់គ្រាប់បែបបន្ទុះកំពុងផែរផើល ហើយហ៊ីត្លែរបានដាក់គ្រាប់បែបនៅទីក្រុងឡុង លោកឆើចឆីលបាននៅក្នុងសតវិមានជាមួយលោកប្រធានាតិបតី ហ្វ្រែងលីន ដ រូស៊ីវែល។ នៅពេលលោកប្រធានាតិបតីបានដុតភ្លើងលើដើមឈើណូអែល នោះលោកឆើចឆីលបាននិយាយថា «សូមឲ្យក្មេងៗសប្បាយនឹងល្បែងកំសាន្ត និងរាត្រីរបស់គេ»។

*អ្នកអាចអានសេចក្តីអធិប្បាយសរសេរតាមពាក្យមួយៗ និងមេរៀនចំនួនរាប់រយក្នុងភាសាចំនួន៤៥នៅតាមគេហទំព័រ*
***WWW.SERMONSFORTHEWORLD.COM.***

តែអ្នក និងខ្ញុំមិនមែនជា «កូនក្មេង»ទៀតឡើយ! នេះគឺជាពេលដើម្បីយល់ដឹងថា ទីសង្ឃឹមតែ១គត់របស់យើងស្ថិតលើទារកដែលបានប្រសូតក្នុងក្រុងយេរូសាឡឹម ហើយត្រូវដឹងថា យើងគ្មានសង្ឃឹមណាផ្សេងឡើយ មានសង្ឃឹមតែក្នុងការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវដ៏ជាស្តេចលើសអស់ទាំងស្តេច និងជាព្រះអម្ចាស់លើសអស់ទាំងព្រះអម្ចាស់ប៉ុណ្ណោះ។

ក្នុងឆ្នាំ១៩៥០ យូរមកហើយ ព្រះបានប្រទានខគម្ពីរមួយដែលដោតជាប់ក្នុងចិត្តយ៉ាងជ្រៅក្នុងនាមជាគ្រូគង្វាលនៅសម័យដែលមនុស្សបោះបង់ចោលព្រះ។

«ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចំរើនកំឡាំងដល់ខ្ញុំ» (ភីលីព ៤:១៣)។

នៅថ្ងៃសុក្រ ទី២ យើងបានប្រារព្ធពិធីចូលឆ្នាំចិននៅកម្មវិធីព្រឹក និងល្ងាច។

កាលពីខែមិនា ខ្ញុំបាននៅអាគារចាស់ថ្ងៃអាទិត្យចុងក្រោយនៅផ្លូវហូផ។ សម្រាប់ពេញឆ្នាំ២០២០ យើងបានជួបជុំគ្នាក្នុងផ្ទះចំនួន២ ដោយសារជំងឺកូរ៉ូណា។ រាល់អាទិត្យ ខ្ញុំថតមេរៀនជាវីដីអូ ដែលត្រូវបានចាក់ក្នុងផ្ទះចំនួន២។ បន្ទាប់មកពីការបង្រៀនតាមវីដីអូ យើងហូបអាហារពេលល្ងាច។

ខួបកំណើតអាយុ៧៩ឆ្នាំរបស់ខ្ញុំជាថ្ងៃអាទិត្យចំបុណ្យរំលឹកពីការរស់ឡើងវិញរបស់ព្រះយេស៊ូវ ខែមេសារ ១២។ យើងក៏បានធ្វើខួបកំណើតអ្នកស្រី ហាយមើស៍នៅខែមេសា ១៦ផងដែរ។ ខ្ញុំអាចនិយាយថា «មានស្រីៗជាច្រើនបានប្រព្រឹត្តដោយគ្រប់លក្ខណ៍ តែនាងបានវិសេសលើសជាងគេទាំងអស់» (សុភាសិត ៣១:២៩)។

នៅខែកញ្ញា ២៧ ក្រុមជំនុំបានធ្វើខួប៣៨ឆ្នាំ។ សម្រាប់ច្រើនឆ្នាំពីមុន ខ្ញុំបានរងទុក្ខពីជំងឺដ៏រាំរៃដែលនាំឲ្យខ្ញុំមិនអាចក្រោកឈរអធិប្បាយបាន។ វាជាការភាយចេញពីជំងឺមហារីកដែលបានបំផ្លាញសរសៃប្រសាទ ដូចជាជំងឺរបស់លោកក្រោនដែរ។

ប៉ុន្តែនៅឆ្នាំដដែលនោះព្រះបានប្រទានពរដល់ការងាររបស់យើង! យើងបានបន្ថែមភាសា៣ទៀតដែលមានការសិក្សានិងសេចក្តីព្រះគម្ពីរតាមខគម្ពីរមួយទៅមួយនៅលើគេហទំព័ររបស់យើងនៅគេហទំព័រ www.sermonsfortheworld.com ។ យើងបានបន្ថែមភាសាខុងសូឈីនដែលជាភាសាក្នុងស្រុករបស់មីយ៉ាន់ម៉ា(ភូមា)ជាភាសាទី៤៣របស់យើង។ យើងបានបន្ថែមម៉ាឡាយ៉ាឡាជាភាសាមួយទៀតរបស់ឥណ្ឌាដែលជាភាសាទី៤៤របស់យើង។ ហើយបន្ទាប់មក យើងបន្ថែមស៊ីនហាឡាជាភាសាស្រីលង្កាជាភាសាទី ៤៥ របស់យើង។

រាល់អាទិត្យ ខ្ញុំបានទទួលអ៊ីម៉ែលអស្ចារ្យៗពីគ្រូអធិប្បាយពាសពេញពិភពលោកដោយប្រាប់យើងពីរបៀបដែលមេរៀង និងសេចក្តីទាំងនោះបានជួយពួកគេ។

នៅថ្ងៃទីខែកក្កដា ៧ វិស្សមកាលបានបើកនៅលើអាគារចាស់របស់យើងនៅលើផ្លូវហូផ អរគុណខ្លាំងណាស់ចំពោះការងារដែលកូនប្រុសរបស់យើងរ៉ូប៊ឺតបានធ្វើ។

នៅថ្ងៃទី ១៣ ខែតុលា ក្រុមជំនុំទាំងមូលបានធ្វើពិធីពីធីសពរបស់លោកអ៊ូហ្គេន គ្រេស៍នៅកន្លែងបញ្ចុះសពរីវើសាយណាសិនណោល។ លោកខាហ្គិនបានដឹកនាំលោកគ្រេស៍ឲ្យជឿលើព្រះយេស៊ូវពីរបីម៉ោង មុនពេលគាត់បានទទួលមរណភាពនៅអាយុ៩១ ឆ្នាំ។ លោកគ្រេស៍ជាឪពុកចុងរបស់ថោម សៀ ជាសមាជិកដ៏ល្អរបស់ក្រុមជំនុំយើង។ ពីរបីសប្តាហ៍ក្រោយមក លោកខាហ្គិនបាននាំដំណឹងល្អដល់ភរិយារបស់លោកគ្រេស៍ ឈ្មោះសុភីយ៉ា ហើយឥឡូវនេះនាងមានជីវិតអស់កល្បជានិច្ច។ នាងសង្ឃឹមថានឹងក្លាយជាមនុស្សទីមួយដែលយើងធ្វើពិធីជ្រមុជទឹកនៅទីតាំងថ្មីរបស់យើងនៅសាន់ហ្គារៀ។ លោកស្រីហាយមើស៍បានដឹកខ្ញុំទៅមាត់ទន្លេដើម្បីចូលរួមកម្មវិធីបុណ្យសពរបស់លោកគ្រេស៍។ បន្ទាប់មកទៀត នាងបានបើកឡានខ្ញុំទៅអោសណាដ ជាកន្លែងដែលយើងចំណាយពេលពីរបីថ្ងៃសម្រាកនៅក្បែរឆ្នេរ។

នៅខែវិច្ឆិការ ២២(ថ្ងៃអាទិត្យ) យើងនឹងមានជប់លៀងថ្ងៃអរគុណដល់ព្រះនៅផ្ទះរបស់លោកខាហ្គិននៅអាលហាប្រ៉ា។ ខ្ញុំនៅតែធ្វើការ សរសេរមេរៀន និងសេចក្តីអធិប្បាយ ថែមទាំងជួយលោក ខាហ្គិន។ ប៉ុន្មានអាទិត្យខាងមុខ ខ្ញុំនឹងមានអាយុ៨១ឆ្នាំ។ ខ្ញុំមិនអាចធ្វើការបានទៀតទេ បើវាមិនមែនសម្រាប់ប្រពន្ធដ៏វិសេសរបស់ខ្ញុំ អែលីណា និងសម្រាប់ព្រះយេស៊ូវដែលខ្ញុំបានទទួលកំលាំងដើម្បីបន្តដំណើរទៅមុខ។

*អ្នកអាចអានសេចក្តីអធិប្បាយសរសេរតាមពាក្យមួយៗ និងមេរៀនចំនួនរាប់រយក្នុងភាសាចំនួន៤៥នៅតាមគេហទំព័រ*
***WWW.SERMONSFORTHEWORLD.COM.***

«ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចំរើនកំឡាំងដល់ខ្ញុំ»(ភីលីព ៤:១៣)។

នេះគឺជាការសន្យារបស់ព្រះយេស៊ូវ! ខ្ញុំនឹងបញ្ចប់សំបុត្រនេះដោយដងស្រង់ទីបន្ទាល់របស់ដៃគូរបស់ខ្ញុំ លោកបណ្ឌិតគ្រីស្តោហ្វឺ អ៊ីល ខាហ្គិនៈ

> ច្រើនឆ្នាំមុន ខ្ញុំគ្មានសេចក្តីសុខសាន្តឡើយ។ ខ្ញុំបានរស់នៅសម្រាប់ខ្លួនឯង។ ខ្ញុំមិនគិតអំពីព្រះ ឬអ្វីដែលនឹងកើតឡើងពេលខ្ញុំស្លាប់ឡើយ។ ខ្ញុំបានទុកចិត្តលើខ្លួនឯង។ ខ្ញុំបានរត់ និងលាក់ខ្លួនពីព្រះ ខ្ញុំរៀនបាននិន្ទេសអេក្នុងមហាវិទ្យាល័យ ហើយខ្ញុំរកលុយបានច្រើន តែខ្ញុំឯកោរ ហើយមិនសប្បាយ។
>
> ក្រោយមកខ្ញុំបានជួបគ្រីស្ទានមួយចំនួនដែលបានធ្វើល្អដល់ខ្ញុំ។ ខ្ញុំចាប់ផ្តើមទៅក្រុមជំនុំ។ តែខ្ញុំនៅតែចង់នៅសម្រាប់ផ្លូវខ្លួនឯង។ នៅយប់មួយ ខ្ញុំបានទៅប្រជុំនៅសាលា។ បុរសក្មេងម្នាក់បានប្រាប់ខ្ញុំពីដំណឹងល្អដែលខ្ញុំបានលឺ គឺថា ព្រះស្រឡាញ់ខ្ញុំ ហើយចង់ប្រទានជីវិតអស់កល្បជានិច្ចដល់ខ្ញុំ។ គាត់បានប្រាប់ខ្ញុំពីរបៀបដើម្បីទទួលបានជីវិតនោះ។ នៅយប់នោះហើយខ្ញុំបានទទួលជឿលើព្រះយេស៊ូវ។ ទ្រង់បានអត់ទោសបាបខ្ញុំ ហើយប្រទានជីវិតអស់កល្បជានិច្ចដល់ខ្ញុំ។
>
> ឥឡូវខ្ញុំមានសេចក្តីសុខសាន្ត ឥឡូវខ្ញុំមានជីវិតអស់កល្បជានិច្ច។ ព្រះយេស៊ូវបានប្រោសខ្ញុំនៅខាងក្នុង។ ទ្រង់ប្រទានទីសង្ឃឹម និងសុភមង្គលដល់ខ្ញុំ។ ខ្ញុំឈប់ឯកោរទៀតហើយ។ ខ្ញុំដឹងថា បើខ្ញុំស្លាប់យប់នេះ ខ្ញុំនឹងទៅនៅជាមួយព្រះនៅស្ថានសួគ៌ ដោយសារព្រះយេស៊ូវបានប្រទានជីវិតអស់កល្បជានិច្ចដល់ខ្ញុំ។

ខ្ញុំសប្បាយចិត្តណាស់ដើម្បីបំរើព្រះយេស៊ូវ! ខ្ញុំមិនអាចបំរើព្រះដោយគ្មានអំណាច និងព្រះគុណរបស់ព្រះ និងដោយគ្មានលោកខាហ្គិន អៃលីណា និងកូនប្រុសរបស់យើងដ៉ោន វ៉ែស្លី ដែលនឹងរៀនខាងការវះកាត់សរសៃឈាម និងមុខវិជ្ជាផ្សេងនៅមហាវិទ្យាល័យនៅរដ្ឋចផ្លារីកខាងមុខ។

សូមឲ្យព្រះយេស៊ូវប្រទានពរអ្នក និងគ្រួសារអ្នក! សូមអធិស្ឋានសម្រាប់លោក ខែនថ៍ ភីលផូត និងខ្ញុំ កាលយើងផ្ទៀងផ្ទាត់សៀវភៅរបស់លោកខែថ៍អំពីការចែកចាយតាមរយៈព្រះយេស៊ូវ! សូមអធិស្ឋានឲ្យយើង កាលយើងទៅចាប់ផ្តើមក្រុមជំនុំប៉ាទីស្ទចិននៅសានហ្គាប្រីអែល។



លោកបណ្ឌិតហាយមើស៍ជាមួយប្រពន្ធរបស់គាត់ អៃលីណា កូនប្រុសរបស់គាត់រ៉ូប៊ឺត ប្រពន្ធរបស់រ៉ូប៊ឺត ជីន និងកូនស្រីទាំង២របស់រ៉ូប៊ឺត ហាណា និងសារ៉ា។ ខ្ញុំនឹងអធិស្ឋានថា គេនឹងមានកូន១ទៀតឆាប់ៗ។

សូមឲ្យព្រះគ្រិស្តត្រូវបានដំកើងឡើងជារៀងរហូត!



លោកវេវ អោ អ៊ឹល ហាយមើស៍ ជេអោ
D.Min., D.Rel., Th.D., Litt.D.
ភីលីព ៤:១៣

«អ្នកណាដែលវង្វេងចេញពីផ្លូវនៃប្រាជ្ញា នោះនឹងសំរាកនៅក្នុងចំណោមមនុស្សស្លាប់ហើយ»(សុភាសិត ២១:១៦)។

*អ្នកអាចអានសេចក្តីអធិប្បាយសរសេរតាមពាក្យមួយៗ និងមេរៀនចំនួនរាប់រយក្នុងភាសាចំនួន៤៥នៅតាមគេហទំព័រ*
***WWW.SERMONSFORTHEWORLD.COM.***